ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់
កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
"ក.ប.ប."

លេខ:..........✓............អ.កបប

ថ្ងៃចន្ទ ៣ រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់ និងការប្រកួតប្រជែង «ក.ប.ប.» នៃក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាម្ចាស់ក្រុមហ៊ុន/សហគ្រាសសិប្បករ ពាណិជ្ជករ អាជីវករ និងសាធារណជន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា៖ ក្នុងគោលបំណងអនុវត្តឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពនូវបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់សកម្មភាពឆ្លៀតឱកាស*នាំចូល ចែកចាយ ផ្គត់ផ្គង់* ផលិតផលទំនិញដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព ឬផលិតផលទំនិញជាប់បម្រាមនាំចូល ឬផលិតផលមានប្រភពមិនច្បាស់លាស់ និង ដើម្បីធានាបាននូវការធ្វើធុរកិច្ចប្រកបដោយសុចរិត និងការពារបាននូវសុខុមាលភាពសាធារណៈ អគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម សូមធ្វើការណែនាំដូចខាងក្រោម៖

- ចំពោះពាណិជ្ជករ អាជីវករជាអ្នកនាំចូល លក់ និងចែកចាយ៖ *មិនត្រូវនាំចូល លក់ ចែកចាយ ផ្គត់ផ្គង់* នូវផលិតផលទំនិញមានផ្ទុកសារធាតុគីមីហាមឃាត់ឬកែច្នៃលួចលាយសារធាតុដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាពអ្នកប្រើប្រាស់ ឬផលិតផលទំនិញជាប់បម្រាមនាំចូល ឬផលិតផលមានប្រភពមិនច្បាស់លាស់ ឬផលិតផលមិនមានភាពអនុលោម *ជាដាច់ខាត* និងត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍សុវត្ថិភាពផលិតផល ជាពិសេសផលិតផលម្ហូបអាហារ ជាអាទិ៍ លក្ខខណ្ឌទុកដាក់ កត្តាអនាម័យ ការវេចខ្ចប់ ការដឹកជញ្ជូន ការចែកចាយ និងការផ្គត់ផ្គង់
- ចំពោះពាណិជ្ជករ អាជីវករជាអ្នកលក់ ចែកចាយបន្ត៖ *មិនត្រូវលក់ ចែកចាយ*ផលិតផលទំនិញដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព ឬផលិតផលមានប្រភពមិនច្បាស់លាស់ ឬផលិតផលមិនមានភាពអនុលោម ព្រមទាំងសុំឱ្យអ្នកផ្គត់ផ្គង់ទំនិញផ្តល់វិក្កយបត្រសម្រាប់ប្រើប្រាស់ជាឯកសារសម្អាង និងត្រូវសហការជាមួយអគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម ដើម្បីអនុវត្តនីតិវិធីអង្កេតដានស្វែងរកប្រភពផលិតនាំចូលចែកចាយនូវផលិតផលទាំងនោះ និងការយកសំណាកគំរូមកវិភាគនៅមន្ទីរពិសោធន៍ដើម្បីស្វែងរកមុខសញ្ញានៃគ្រោះ ជាយថាហេតុ ជាពិសេស ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍សុវត្ថិភាពផលិតផលសម្រាប់លក់ជូនអ្នកប្រើប្រាស់
- ចំពោះអ្នកប្រើប្រាស់ និងសាធារណជន៖ សូមយកចិត្តទុកដាក់ បង្កើនការប្រុងប្រយ័ត្ន និង*សូមជៀសវាងការទិញ*ផលិតផលដែលសង្ស័យថាមានផ្ទុកសារធាតុគីមីហាមឃាត់ឬកែច្នៃលួចលាយសារធាតុដែលអាច



អាសយដ្ឋាន: ផ្លូវ 18 ភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កម្ពុជា | ទូរស័ព្ទ (+855) 23 231 856 | (+855) 92 830 856
គេហទំព័រ: www.ccfdg.gov.kh

បង្កគ្រោះថ្នាក់ដល់សុខភាព ឬផលិតផលមានប្រភពមិនច្បាស់លាស់ ដែលបាននិងកំពុងលក់ ចែកចាយ ផ្គត់ផ្គង់ ក្នុងទីផ្សារ ព្រមទាំងរាយការណ៍មកអគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម ដើម្បីមានវិធានការណ៍តាមនីតិវិធីនៃច្បាប់ជាធរមាន។

អគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម សង្ឃឹមយ៉ាងមុតមាំលើស្មារតីសហការពីបណ្តាស្ថាប័នមានសមត្ថកិច្ច និងអ្នកនាំចូល អ្នកលក់ អ្នកចែកចាយ អ្នកផ្គត់ផ្គង់ អ្នកប្រើប្រាស់ សាធារណជន ព្រមទាំងតួអង្គពាក់ព័ន្ធរួមគ្នាបំពេញកាតព្វកិច្ច ដើម្បីគោលដៅរួមក្នុងការការការពារសុខភាព សុវត្ថិភាពយើងទាំងអស់គ្នា និងសូមសហការផ្តល់ព័ត៌មានមកអគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម តាមរយៈប្រព័ន្ធទូរសព្ទសាធារណៈក្រសួងពាណិជ្ជកម្ម លេខ ១២៦៦។

កម្មវិធី CCF Complaint App

**ប្រព័ន្ធទូរសព្ទសាធារណៈ**
**ក្រសួងពាណិជ្ជកម្ម**
**1266**

សូមអរគុណ!